# សេវាបន្ថែម

អ្នកអាចនឹងទទួលសេវាផ្សេងៗទៀត ដើម្បីទ្រទ្រង់ខ្លួនអ្នក និងគ្រួសាររបស់អ្នក ក្នុងខណៈអ្នកធ្វើការឲ្យបានសំរេចគោលដៅ Cal-Learn របស់អ្នក។ សេវាបន្ថែមអាចនឹងរួមមានទូវ :

## WIC

កម្មវិធីសំរាប់ស្ត្រី ទារក និង កុមារ ដែលគ្រប់ៗគ្នាស្គាល់ថា WIC គឺជាកម្មវិធីផ្តល់អាហារ និងជីវជាតិបន្ថែម ដែលអាចនឹងផ្តល់ឲ្យអ្នកនូវការអប់រំអំពីអាហារជីវជាតិ អាហារមានសុខភាពល្អ និងឱវាទការបំបៅដោះកូន។

## CalFresh

តាមរយៈកម្មវិធីនេះ អ្នកអាចនឹងទទួលជំនួយ ដើម្បីទិញម្ហូបអាហារ សំរាប់គ្រួសាររបស់អ្នក។

## Medi-Cal

តាមរយៈកម្មវិធី Medi-Cal អ្នកអាចនឹងទទួលការថែទាំមុនពេលឆ្លងទន្លេ និងពិនិត្យសុខភាពបន្ទាប់ពីកូនង៉ែតរបស់អ្នកបានកើត។ អ្នកក៏អាចនឹងមានសិទ្ធិទទួលការថែទាំសុខភាពទូទៅផងដែរ។ កូនង៉ែតរបស់អ្នកក៏អាចនឹងទទួលការថែទាំសុខភាព ដូចជាការចាក់ថ្នាំការពាររោគ និងការថែទាំសុខុមាលភាពកូនង៉ែត។



## សេវារៀបចំគំរោងការគ្រួសារ

កាលណាកូនង៉ែតរបស់អ្នកបានកើតហើយ អ្នកនឹងចង់គិតគូរអំពីជំរើសបង្ការកុំឲ្យមានកូន។ សេវារៀបចំគំរោងគ្រួសារឥតអស់ថ្លៃ និងមានតម្លៃថោក គឺមានសំរាប់ជួយអ្នកឲ្យធ្វើការនោះបាន។ វេជ្ជបណ្ឌិតរបស់អ្នកអាចផ្តល់ឱវាទអ្នក ថារបៀបណាមួយដែលល្អប្រពៃសំរាប់អ្នក។ វាជាសារៈសំខាន់ត្រូវកត់សំគាល់ថា ស្ត្រីអាចមានផ្ទៃពោះម្តងទៀត ក្នុងខណៈបំបៅដោះកូនង៉ែតរបស់នាង។

**សេវាគាំទ្រផ្សេងៗទៀត ក៏មានផងដែរ។ សូមពិគ្រោះជាមួយនឹងអ្នកកាន់សំណុំរឿងរបស់អ្នក សំរាប់ព័ត៌មាន និងជំនួយបន្ថែម។**

ប្រអប់ត្រាខោនធី

**សំរាប់ព័ត៌មានបន្ថែម អំពី Cal-Learn សូមទាក់ទង :**

មនុស្សទាំងអស់នៅក្នុងរូបថតនេះ គឺជាគំរូ និងបានប្រើសំរាប់គោលបំណងនៃការបង្ហាញតែប៉ុណ្ណោះ។

**State of California**
រដ្ឋកាលីហ្វ័រនីញ៉ា
**Health and Human Services Agency**
ភ្នាក់ងារសេវាសុខភាព និងមនុស្ស
**Department of Social Services**
នៃក្រសួងសង្គមកិច្ច
**PUB 367 (CB) (04/13)**



# ឈោងចាប់សុបិនរបស់អ្នក ជាមួយនឹង Cal-Learn



**ជាកម្មវិធីមួយទូទាំងរដ្ឋ ដើម្បីជួយស្ត្រីមានផ្ទៃ និងមាតាបិតាវ័យជំទង់ ដែលកំពុងទទួល CalWORKs/TANF ឲ្យបញ្ចប់វិទ្យាល័យ និង ក្លាយជាឯករាជ្យម្ចាស់ការ និងបង្កើតជាគ្រួសារមានសុខភាពល្អ។**

# តើ Cal-Learn ជាអ្វី?

Cal-Learn គឺជាកម្មវិធីមួយទូទាំងរដ្ឋ សំរាប់ស្ត្រីមានផ្ទៃពោះ និងជាមាតាបិតាវ័យជំទង់ ដែលទាំងម្តាយ និងឪពុក ទទួលជំនួយ CalWORKs/ TANF។ វាមិនមែនជាសាលារៀនទេ។ គោលបំណងនៃ Cal-Learn គឺដើម្បីជួយយុវវ័យឲ្យទទួលសញ្ញាប័ត្រពីវិទ្យាល័យ ឲ្យបានក្លាយជាឯករាជ្យម្ចាស់ការ និងបង្កើតជាគ្រួសារមានសុខភាពល្អ។

## តើខ្ញុំត្រូវចូលរួម ឬទេ?

បើអ្នកមានផ្ទៃពោះ ឬជាមាតាបិតាយុវវ័យ កំពុងទទួលជំនួយ CalWORKs/TANF អ្នកត្រូវតែចូលរួមក្នុង Cal-Learn។ ពួកវ័យជំទង់ខ្លះអាចបានលើកលែងពីកម្មវិធី ឬពន្យារពេលការចូលរួមនៅក្នុងកាលៈទេសៈពិសេស។

## ដើម្បីឲ្យមានសិទ្ធិទទួល Cal-Learn អ្នកត្រូវតែ :

- រស់នៅក្នុងក្រុមគ្រួសារ ដូចគ្នានឹងកូនរបស់អ្នក
- ក្រោមអាយុ 19 ឆ្នាំ
- ពុំទាន់មានសញ្ញាប័ត្រវិទ្យាល័យ ឬ GED
- មិននៅក្នុងការថែទាំកូនចិញ្ចឹម



**សំរាប់ព័ត៌មាន និងសេចក្តីល្អិតល្អន់បន្ថែម អំពីការចូលរួមរបស់អ្នកក្នុង Cal-Learn សូមពិគ្រោះជាមួយនឹងបុគ្គលិកនៃកម្មវិធី Cal-Learn នៅខោនធីរបស់អ្នក។**

# ការបានសញ្ញាប័ត្រឌីផ្លូម របស់អ្នក

កាលណាអ្នកនៅក្នុង Cal-Learn អ្នកនឹងមានអ្នកកាន់សំណុំរឿងម្នាក់ ដែលនឹងជួយអ្នកបង្កើតគំរោងការដើម្បីបញ្ចប់វិទ្យាល័យ ឬឲ្យបាន GED។ បើនៅពេលបច្ចុប្បន្ននេះអ្នកមិនទៅសាលាទេ អ្នកកាន់សំណុំរឿងរបស់អ្នកនឹងជួយអ្នក ឲ្យវិលត្រឡប់ទៅសាលាវិញ ឬរកសាលាត្រឹមត្រូវស្របតាមសេចក្តីត្រូវការរបស់អ្នក។ កម្មវិធីរួមមាន :



**ការប៉ាន់ប្រមាណ** ដើម្បីសំរេចថាសេវា និងការគាំទ្រអ្វីខ្លះដែលអ្នកត្រូវការ ប្រយោជន៍ឲ្យស្របតាមគោលដៅការសិក្សារបស់អ្នក។

**បង្កើតគំរោងការមួយ** ប្រយោជន៍ឲ្យអ្នកអាចទទួលសេវាដែលអ្នកត្រូវការ និងអាចចូលទៅសាលារៀន។

**ចាត់វិធានការ** ដើម្បីជួយអ្នកឲ្យទៅដល់គោលដៅរបស់អ្នក។

**ការតាមដាន** ដើម្បីធ្វើឲ្យប្រាកដថាអ្នកកំពុងតែជឿនលឿន ឆ្ពោះឲ្យបានសញ្ញាប័ត្រឌីផ្លូម ឬ GED និងស្របតាមគោលដៅផ្សេងៗទៀត។

**ពិនិត្យមើលគំរោងការ ជាម្តងម្កាល** ដើម្បីសំគាល់អ្វីដែលមានប្រសិទ្ធិភាព និងអ្វីដែលគ្មានប្រសិទ្ធិភាព។

# បានប្រាក់បំណាច់ ឬ ទណ្ឌកម្ម

Cal-Learn ឲ្យរង្វាន់ដល់ការសិក្សាបានល្អ និងដាក់ពិន័យដល់ការសិក្សាមិនបានល្អ។

## ធ្វើបានល្អ និងបានប្រាក់បំណាច់ :

ទទួលពិន្ទុល្អ និងប្រគល់មកនូវប័ណ្ណរបាយការណ៍របស់អ្នកម្តងៗ វាត្រូវបានចេញឲ្យ = $100 បានបន្ថែមទៅលើប្រាក់សម្បទាននៃគ្រួសាររបស់អ្នក សំរាប់រយៈពេលនៃប័ណ្ណរបាយការណ៍ម្តងៗ។ ទទួលសញ្ញាប័ត្រពីវិទ្យាល័យ = $500 បានឲ្យទៅអ្នក។

## ធ្វើមិនបានល្អ និងបានទណ្ឌកម្ម :

ទទួលពិន្ទុជាមធ្យមក្រោម D និងអាក់ខានប្រគល់មកនូវប័ណ្ណរបាយការណ៍របស់អ្នកម្តងៗ វាត្រូវបានចេញឲ្យ = $100 បានដកចេញពីប្រាក់សម្បទាននៃគ្រួសាររបស់អ្នក សំរាប់រយៈពេលនៃប័ណ្ណរបាយការណ៍ម្តងៗ។

# ការចាត់ចែងករណី សំរាប់ភាពជោគជ័យរបស់អ្នក

អ្នកកាន់សំណុំរឿងរបស់អ្នក នឹងជួយអ្នកថែមទៀត មិនគ្រាន់តែការសិក្សាទេ។ មានសេវាគាំទ្រជាច្រើន ដែលអាចនឹងមានសំរាប់ជួយអ្នក ឲ្យឆ្លងកាត់ឧបសគ្គដែលអ្នកប្រឈមមុខ ឋានៈជាមាតាបិតាយុវវ័យ ដូចជា :

## ការចំណាយថ្លៃថែទាំកូន

កម្មវិធី Cal-Learn អាចនឹងជួយអ្នកបង់ថ្លៃថែទាំកូន ក្នុងខណ: អ្នកទៅសិក្សា។ បើអ្នកកំពុងធ្វើការ និងទៅសិក្សា អ្នកក៏អាចនឹងមានសិទ្ធិទទួលប្រាក់ថែទាំកូន ក្នុងខណៈអ្នកទៅធ្វើការផងដែរ។

## ការចំណាយថ្លៃសាលា

ការប្រឡង GED ថ្លៃសៀវភៅ និងថ្លៃឈ្នួលការពិសោធន៍ គឺជាវត្ថុខ្លះៗដែលកម្មវិធី Cal-Learn អាចនឹងជួយអ្នកទិញសំរាប់សាលា។

## ការចំណាយថ្លៃយានជំនិះ

អ្នកអាចនឹងទទួលជំនួយ សំរាប់ការបង់ថ្លៃយានជំនិះ ដើម្បីទៅ និងមកពីសាលា។

## សេវាគាំទ្រ

អ្នកកាន់សំណុំរឿងរបស់អ្នក អាចនឹងផ្តល់ឲ្យអ្នកនូវការបញ្ជូនទៅភ្នាក់ងារផ្សេងៗទៀត ដោះស្រាយជាមួយនឹងបញ្ហាជាច្រើន ដែលអ្នកអាចនឹងប្រឈមមុខ រួមមាននូវ :

- រឿងរ៉ាវខាងច្បាប់
- អំពើហិង្សាក្នុងគ្រួសារ
- រឿងរ៉ាវសុខភាព
- ទីលំនៅ